# ជំពូកទី 1. ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងបញ្ហាប្រឈម

នៅឆ្នាំ 2025 សេដ្ឋកិច្ចពិភពលោកបានឆ្លងកាត់ឆ្នាំដ៏ច្របូកច្របល់មួយ ដែលរក្សាបាននូវកំណើនថេរចំពេល មានការប្រែប្រួលដ៏សំខាន់លើនយោបាយពាណិជ្ជកម្មក្នុងប៉ុន្មានទសវត្សរ៍មកនេះ។ វិធានការពន្ធគយដែលបានប្រកាសដោយសហរដ្ឋអាមេរិកកាលពីខែមេសា បានជំរុញឱ្យមានភាពមិនប្រាកដប្រជាលើគោលនយោបាយពាណិជ្ជកម្មឈានដល់កម្រិតខ្ពស់ជាប្រវត្តិសាស្ត្រ ប៉ុន្តែជាលទ្ធផលវិញ ហាក់បានបង្ហាញពីភាពធូរស្រាលជាងការណ៍ដំបូង ទន្ទឹមនឹងការផលប៉ះពាល់ផ្នែកម៉ាក្រូសេដ្ឋកិច្ច ក៏ត្រូវបានរក្សាបានល្អជាងការរំពឹងទុកផងដែរ។ សេដ្ឋកិច្ចសហរដ្ឋអាមេរិកបានបន្តពង្រីកក្នុងល្បឿនដ៏រឹងមាំ ដែលគាំទ្រដោយតម្រូវការក្នុងស្រុក និងការវិនិយោគលើបញ្ញាសិប្បនិម្មិត (AI)។ កំណើននៅតំបន់អឺរ៉ូនៅតែមានភាពធន់ចំពេលដែលមានវិបត្តិនៃរចនាសម្ព័ន្ធផលិតកម្ម និងភាពទន់ខ្សោយនៃតម្រូវការខាងក្រៅ។ អតិផរណាសកលបន្តស្ថិតក្នុងកម្រិតធម្យម ជាមួយនឹងថ្លៃទំនិញទាប និងតម្រូវការទាប ដោយកាត់បន្ថយនូវសម្ពាធថ្លៃនៅខាងក្រៅសហរដ្ឋអាមេរិក បើទោះបីជាការកំណត់ពន្ធបានរក្សាអតិផរណារបស់សហរដ្ឋអាមេរិកឱ្យនៅក្នុងកម្រិតយឺតក៏ដោយ។

សម្រាប់ឆ្នាំ 2025 តំបន់អាស៊ាន+3 សម្រេចបានលើសពីការរំពឹងទុក ដោយកើនឡើងបានដល់ 4,3 ភាគរយខ្ពស់ជាង 3,8 ភាគរយដែលបានព្យាករណ៍ភ្លាមបន្ទាប់ពីការប្រកាសពន្ធគយកាលពីខែមេសា។ មានកត្តា ជាច្រើន បានទ្រទ្រង់លទ្ធផលល្អនេះ រួមមាន៖ តម្រូវការបន្ទះឈីបដ៏រឹងមាំសម្រាប់បញ្ញាសិប្បនិម្មិត (AI) បានរក្សាសន្ទុះនាំចេញពេញមួយឆ្នាំ; ស្ថានភាពពាណិជ្ជកម្មក្នុងតំបន់បានពង្រឹង បើទោះបីជាការដឹកជញ្ជូនទៅកាន់សហរដ្ឋអាមេរិកបានថយចុះក៏ដោយ ក៏ដូចជាការគាំទ្រទាន់ពេលវេលានៃវិធានការផ្នែកគោលនយោបាយ ក្នុងការជួយសម្រួលដល់សកម្មភាពក្នុងស្រុក។ សកម្មភាពប្រើប្រាស់ឯកជននៅតែបង្ហាញ ពីភាពរឹងមាំនៅបណ្តាសេដ្ឋកិច្ចប្រទេសនានា ដែលមានមូលដ្ឋានទីផ្សារការងារអំណោយផល និងអតិផរណាទាប ខណៈពេលដែលស្ថានភាពវិនិយោគ បានកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងតំបន់អាស៊ាន ចំពេលមានលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស (FDI) ជាបន្តបន្ទាប់ទៅក្នុងផលិតផលអេឡិចត្រូនិចទំនើប យានយន្តអគ្គិសនី និងសេវាកម្មឌីជីថល។ អតិផរណានៅតែស្ថិតនៅក្នុងកម្រិតទាប និងមានស្ថេរភាពក្នុងរង្វង់ 0,9 ភាគរយ ទាបជាងមធ្យមភាគរយៈពេលវែងរបស់តំបន់នាឆ្នាំ 2014-2019 ដែលផ្តល់ចន្លោះសម្រាប់បំពេញបន្ថែមដោយគោលនយោបាយរូបិយវត្ថុសមស្រប។ ការកើនឡើងនៃទុនបម្រុងអន្តរជាតិបានពង្រឹងសញ្ញ័យធនរបស់តំបន់ពីសេដ្ឋកិច្ចខាងក្រៅនៅពេលដែលមានការប្រែប្រួលនៅក្នុងឆ្នាំណាមួយ។

កំណើនត្រូវបានព្យាករថានឹងថយចុះមកត្រឹម 4 ភាគរយនៅឆ្នាំ 2026 និង 2027 ដែលភាគច្រើន ក៏ដោយសារតែអត្រាពន្ធខ្ពស់របស់សហរដ្ឋអាមេរិកដែលជះឥទ្ធិពលដល់តម្រូវការខាងក្រៅ។ តម្រូវការក្នុងស្រុកត្រូវបានរំពឹងថានឹងនៅតែជាយុថ្កាសំខាន់ ដែលគាំទ្រដោយសកម្មភាពវិនិយោគបន្ត លំហូរចូល FDI ប្រកបដោយចីរភាព និងសកម្មភាពប្រើប្រាស់ឯកជនរឹងមាំ ស្របពេលដែលមានលក្ខខណ្ឌទីផ្សារការងារអំណោយផល។ តម្រូវការនាំចេញដែលទ្រទ្រង់ដោយបច្ចេកវិទ្យា គួរតែផ្តល់នូវភាពជំនួសមកវិញដ៏សំខាន់មួយ ពោលគឺការនាំចេញបន្ទះឈីប និងឧបករណ៍អេឡិចត្រូនិកមួយចំនួនដែលត្រូវបានរំពឹងថានឹងនៅតែរឹងមាំដោយសារតែការបន្តវិនិយោគលើបញ្ញាសិប្បនិម្មិត AI បើទោះបីជាមានល្បឿនលើសពីឆ្នាំ២០២៥ ក៏ដោយ។ អតិផរណា ត្រូវបានព្យាករថានឹងកើនឡើងដល់ 1,4 ភាគរយនៅឆ្នាំ 2026 និង 1,5 ភាគរយនៅឆ្នាំ 2027 ដែលភាគច្រើនឆ្លុះបញ្ចាំងពីតម្លៃថាមពលសកលកាន់តែខ្ពស់ និងការធ្វើវិចារណកម្មឧបត្ថម្ភធននៅក្នុងសេដ្ឋកិច្ចប្រទេសមួយចំនួន។

តុល្យភាពនៃហានិភ័យទៅលើទស្សនវិស័យត្រូវបានផ្អៀងទៅរកការធ្លាក់ចុះ ដោយភាពមិនប្រាកដប្រជានៅតែបន្តកើនឡើង។ តម្រូវការបច្ចេកវិទ្យា និងការផ្លាស់ប្តូរគោលនយោបាយពាណិជ្ជកម្ម បានវិវត្តទៅជាប្រភពនៃហានិភ័យទ្វេភាគី។ ការសម្របខ្លួននឹង AI និងការចំណាយមូលធនខ្លាំងជាងការរំពឹងទុក អាចទាញកំណើនឱ្យលើសពីកម្រិតមូលដ្ឋាន ខណៈដែលឧបសគ្គនៅក្នុងវដ្តបច្ចេកវិទ្យា ឬការកើនឡើងពន្ធគយជាថ្មី អាចនឹងបន្ថែមទម្ងន់ជាសារវន្តលើសកម្មភាពក្នុងតំបន់។ ការកើនឡើងនៃតម្លៃថាមពលសកល និងលទ្ធភាពដែលអាចរំខានដល់ការផ្គត់ផ្គង់ថាមពលប្រកបដោយចីរភាព ក៏អាចបង្កឱ្យមានហានិភ័យបន្ថែមទៀតចំពោះកំណើន ទន្ទឹមនឹងការបន្ថែមសម្ពាធអតិផរណាផងដែរ។ ក្រៅពីនេះ ភាពប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុ និងកំណើនខ្សោយជាងការរំពឹងទុកនៅក្នុងប្រទេសសេដ្ឋកិច្ចធំៗ នៅតែបន្តបង្កហានិភ័យអវិជ្ជមានដល់តំបន់។ លើសពីនេះ ការប្រែប្រួលទីផ្សារហិរញ្ញវត្ថុ និងកំណើនខ្សោយជាងការរំពឹងទុកនៅក្នុងបណ្តាប្រទេសដែលមានសេដ្ឋកិច្ចធំៗ នៅតែអាចបន្តបង្កជាហានិភ័យធ្លាក់ចុះដល់តំបន់។

ការរក្សានូវភាពបត់បែននៃគោលនយោបាយ គឺជាបញ្ហាចោទដ៏ចម្បងសម្រាប់អ្នកធ្វើគោលនយោបាយអាស៊ាន+3 ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ។ តំបន់នេះចូលដល់ឆ្នាំ ២០២៦ ពីគោលជំហរដែលពឹងផ្អែកលើកិច្ចទំនាក់ទំនងដ៏រឹងមាំ កំណើនលើសពីការរំពឹងទុកនៅឆ្នាំ ២០២៥ អតិផរណានៅតែទាប ហើយសេដ្ឋកិច្ចភាគច្រើនរក្សាលំហសារពើពន្ធ និងរូបិយវត្ថុបានយ៉ាងល្អប្រសើរ។ សារៈសំខាន់ក្នុងការរក្សាភាពបត់បែននោះ ឆ្លុះបញ្ចាំងពីភាពមិនប្រាកដប្រជាដែលស្ថិតនៅហ៊ុមព័ទ្ធជុំវិញទស្សនវិស័យ និងលទ្ធផលដែលនឹងកើតឡើងនានា។ វិធីសាស្ត្រពឹងផ្អែកលើទិន្នន័យ និងភាពបត់បែនដែលគាំទ្រដោយការប្រាស្រ័យទាក់ទងច្បាស់លាស់ និងដែលបំពេញបន្ថែមផ្នែកគោលនយោបាយសារពើពន្ធនិងរូបិយវត្ថុ នឹងមានសារៈសំខាន់ខ្លាំងក្នុងការរក្សាសន្ទុះកំណើន ទន្ទឹមនឹងការរក្សាបាននូវសមត្ថភាពក្នុងការឆ្លើយតបទៅនឹងវិបត្តិ។

*Terjemahan ini hanya untuk tujuan informasi saja. Jika terdapat perbedaan, versi asli dalam bahasa Inggris yang akan berlaku.*

EN
ID
MS
ZH
JA
KM
KO
LO
MY
TH
VI

# ជំពូកទី 2. លំនឹងដ៏រឹងមាំនៃអាស៊ាន+3 ក្នុងតំបន់៖ បរិវត្តកម្មនៃការផ្សារភ្ជាប់សេដ្ឋកិច្ច

មជ្ឈដ្ឋានសកលជារួមជុំវិញតំបន់អាស៊ាន+3 មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់។ វិធានការពន្ធគយ ការកំណត់រចនាសម្ព័ន្ធភូមិសាស្ត្រសេដ្ឋកិច្ចកាន់តែទូលំទូលាយ និងភាពមិនច្បាស់លាស់កាន់តែខ្ពស់នៃគោលនយោបាយសកល បានស្តែងចេញនូវសំណួរសំខាន់ៗមួយចំនួនជុំវិញភាពធន់ក្នុងរយៈពេលខ្លី កិច្ចពាណិជ្ជកម្មក្នុងតំបន់ដែលមានលក្ខណៈស៊ីជម្រៅ និងការកំណត់ជំហរសម្រាប់រយៈពេលវែង។ ជំពូកនេះផ្តល់នូវទស្សនៈវិស័យដែលមានលក្ខណៈជារចនាសម្ព័ន្ធចាំបាច់សម្រាប់ការវាយតម្លៃសំណួរទាំងនេះ ពោលគឺការកំណត់ផែនទីនៃរបៀបដែលទំនាក់ទំនងសេដ្ឋកិច្ចរបស់តំបន់បានផ្លាស់ប្តូរក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកដោយពិនិត្យមើលថាតើ នេះមានន័យយ៉ាងណាសម្រាប់ថាមវន្តនៃវដ្តអាជីវកម្ម និងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ក៏ដូចជាពិចារណាពីរបៀបដែលសេដ្ឋកិច្ចអាចកំណត់ទីតាំងរបស់ខ្លួនសម្រាប់ភាពធន់និងកំណើនរយៈពេលវែង។

ទំនាក់ទំនងសេដ្ឋកិច្ចអាស៊ាន+៣ បានឆ្លងកាត់ការផ្លាស់ប្តូរជាមូលដ្ឋានបើធៀបទៅនឹងពីរទសវត្សរ៍មុន ដោយកំណត់ជាទូទៅថាតំបន់នេះជាទីតាំងផលិតកម្មចម្បងដែលបម្រើដល់តម្រូវការខាងក្រៅ។ ចំពោះផ្នែកផ្គត់ផ្គង់បណ្តាញផលិតកម្មក្នុងតំបន់បានវិវត្តពីមជ្ឈមណ្ឌលដែលធ្លាប់តែមាននៅប្រទេសជប៉ុន ទៅជានិម្មាបនកម្មដែលមានការភាពប្រទាក់ក្រឡានិងស៊ីជម្រៅពីសំណាក់ប្រទេសចិន ពោលគឺពាណិជ្ជកម្មក្នុងទម្រង់ជាទំនិញពាក់កណ្តាលសម្រេច និងទំនិញមូលធន ដែលគាំទ្រដល់បណ្តាញផលិតកម្មរួមបញ្ចូលគ្នា។ រីឯផ្នែកតម្រូវការ ការតម្រង់ទិសឡើងវិញក៏បានបង្ហាញពីភាពសំខាន់ដូចគ្នា។ តំបន់អាស៊ាន+៣ បានលេចឡើងថាជាផ្នែកដ៏ធំមួយនៃតម្រូវការ សកល (ធំជាងសហរដ្ឋអាមេរិក) ខណៈដែលបច្ចុប្បន្នតម្រូវការក្នុងតំបន់កាន់ធំជាងពីរទសវត្សរ៍មុន។ ការពឹងផ្អែកគ្នាទៅវិញទៅមក គឺមានលក្ខណៈគ្រប់ជ្រុងជ្រោយ ពោលគឺប្រទេសចិនបំពេញឱ្យតំបន់ តំបន់បំពេញឱ្យប្រទេសចិន និងកាន់តែខ្លាំងឡើងក្នុងចំណោមអាស៊ាន បូក៣ និងចិនជាសមូហភាព។

បរិវត្តកម្មរចនាសម្ព័ន្ធនេះមានន័យថាតំបន់នេះ ស្ថិតនៅក្នុងភាពល្អប្រសើរជាងមុន ដើម្បីទប់ទល់នឹងការរំខានពាណិជ្ជកម្មនាពេលបច្ចុប្បន្ន ជាងការកំណត់រចនាសម្ព័ន្ធដែលធ្លាប់មានពីមុន។ មូលដ្ឋាននៃតម្រូវការក្នុងតំបន់បច្ចុប្បន្នគឺកាន់តែបង្ហាញពីភាពរឹងមាំ ទន្ទឹមនឹងការពឹងផ្អែកតិចតួចជាងមុនទៅលើទីផ្សារខាងក្រៅ។ ការធ្វើសមាហរណកម្មផ្នែកផ្គត់ផ្គង់ គឺឆ្លុះបញ្ចាំងពីការតភ្ជាប់ផលិតកម្មដ៏សំខាន់ដែលបានបង្កប់នៅក្នុងបណ្តាញខ្សែសង្វាក់តម្លៃក្នុងតំបន់ដ៏ស្មុគស្មាញ និងមានភាពស្អិតរមួត ជាជាងការបង្វែរផ្លូវ (Re-routing) ជាមួយនឹងភាពមានកម្រិតនៃការបង្កើតតម្លៃបន្ថែម។ ការណ៍នេះមិនបង្ហាញពីភាពស៊ាំទៅនឹងឧបសគ្គខាងក្រៅទេ ប៉ុន្តែវាផ្តល់នូវកម្រិតនៃភាពធន់ម្យ៉ាង ដែលលក្ខណៈសាមញ្ញមិនអាចបញ្ជាក់បាន។

ការតភ្ជាប់ស៊ីជម្រៅនេះ បានធ្វើឱ្យវដ្តអាជីវកម្មក្នុងតំបន់អាស៊ាន+៣ កាន់តែខិតជិតគ្នា ដោយបច្ចុប្បន្នកត្តាក្នុងតំបន់ក៏បានពន្យល់ពីបំរែបំរួលវដ្តជាច្រើនដូចកត្តាសកលផងដែរ។ ភាពរឹងមាំក្នុងតំបន់កាន់តែប្រសើរនេះបានផ្តល់នូវការការពារមួយចំនួនប្រឆាំងនឹងវិបត្តិតម្រូវការខាងក្រៅ។ នៅពេលជាមួយគ្នានេះ ការរីករាលដាលក្នុងតំបន់ អាចនឹងមានទំហំធំជាងនេះ ប្រសិនបើមានការប៉ះទង្គិចកើតឡើង ដែលការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចក្នុងស្រុកនោះ ជាការព្រួយបារម្ភក្នុងតំបន់ មិនមែនត្រឹមតែក្នុងស្រុកនោះទេ។ កិច្ចទំនាក់ទំនងនិងការឃ្លាំមើលក្នុងតំបន់កាន់តែមានគុណតម្លៃសម្រាប់ការប្រមើលមើលពីភាពងាយរងគ្រោះរួមគ្នា។ ការត្រៀមខ្លួនសម្រាប់វិបត្តិសកលនៅតែមានភាពចាំបាច់៖ កត្តាសកលនៅតែបន្តជាឥទ្ធិពលសំខាន់លើថាមវន្តនៃវដ្តក្នុងតំបន់។ ក្រៅពីការពិចារណាតាមវដ្ត តើសេដ្ឋកិច្ចអាចទ្រទ្រង់ភាពធន់និងកំណើនរយៈពេលវែងនៅក្នុងឧស្សាហកម្មអនុគមន៍ទាំងនេះដោយរបៀបណា? សម្រាប់សេដ្ឋកិច្ចមួយចំនួន ផលដែលទទួលបានពីការផ្លាស់ប្តូរខ្សែច្រវាក់តម្លៃ ក៏មកជាមួយនឹងការកើនឡើងហានិភ័យផងដែរ ដោយការដាក់ចេញនូវបញ្ហាប្រឈមនៃគោលនយោបាយកណ្តាលក្នុងការចាប់យកអត្ថប្រយោជន៍នៃការធ្វើសមាហរណកម្ម ទន្ទឹមនឹងមានការគ្រប់គ្រងភាពងាយរងគ្រោះរបស់ខ្លួនផងដែរ។ អាទិភាពបី កើតឡើង៖ ការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពក្នុងស្រុកឆ្ពោះទៅរកសកម្មភាពបន្ថែមតម្លៃខ្ពស់ ការធ្វើពិពិធកម្មដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និងការចូលរួមប្រកបដោយបរិយាប័ន្ន ដើម្បីឱ្យផលពីការធ្វើសមាហរណកម្មនោះ ត្រូវបានចែករំលែកយ៉ាងទូលំទូលាយ។ សម្រាប់អាស៊ានជាពិសេស ឧបសគ្គដែលមានលក្ខណៈជារចនាសម្ព័ន្ធមានន័យថា ការធ្វើសមាហរណកម្មកាន់តែស៊ីជម្រៅបន្ថែមទៀតដោយតម្រូវឱ្យមានយុទ្ធសាស្ត្រលើសពីការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម ដែលរួមទាំងការលើកកម្ពស់ឧស្សាហកម្មប្រតិគមន៍វិនិយោគក្នុងតំបន់។

ទិដ្ឋភាពនៃការធ្វើសមាហរណកម្មក្នុងតំបន់អាស៊ាន+៣ នឹងបន្តវិវត្ត។ ភាពតានតឹងភូមិសាស្ត្រសេដ្ឋកិច្ចអាចពង្រឹងការតម្រង់ទិសឡើងវិញក្នុងក្របខណ្ឌតំបន់ ការប្រែប្រួលនៃប្រជាសាស្ត្រ និងការធ្វើឱ្យមានតុល្យភាពសេដ្ឋកិច្ច កំពុងធ្វើឱ្យមានតម្រូវការឆ្ពោះទៅរកប្រភពក្នុងតំបន់ បច្ចេកវិទ្យាឌីជីថល និងការផ្លាស់ប្តូរបៃតង កំពុងបង្កើតព្រំដែនសមាហរណកម្មថ្មី។ ការរុករកមជ្ឈដ្ឋាននេះទាមទារឱ្យមានការកសាងសមត្ថភាពនៃការសម្របខ្លួន។ កិច្ចសហប្រតិបត្តិការក្នុងតំបន់នឹងផ្តល់នូវគុណតម្លៃ៖ នៅពេលដែលសេដ្ឋកិច្ចកាន់តែប៉ះពាល់ពីការអភិវឌ្ឍន៍នៅក្នុងប្រទេសជិតខាងរបស់ពួកគេ ករណីសម្រាប់ការសន្ទនាគោលនយោបាយ និងសកម្មភាពរួមគ្នាពង្រឹងណាមួយ។ តំបន់អាស៊ាន+៣ ក៏បានបង្ហាញពីសមត្ថភាពនេះមកហើយដែរ ដែលជាពិសេសតាមរយៈនិម្មាបនកម្មក្នុងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុដែលបានកសាងឡើងជាបន្តបន្ទាប់ពីវិបត្តិហិរញ្ញវត្ថុអាស៊ី។ កំណើនក្នុងតំបន់ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះត្រូវបានកសាងឡើងដោយផ្អែកលើការបើកចំហ សមាហរណកម្ម និងកិច្ចសហប្រតិបត្តិការ ដោយរក្សានិរន្តរភាពនៃគន្លងនោះនៅក្នុងពិភពលោកដែលមិនប្រាកដប្រជា ដែលនឹងតម្រូវឱ្យមានភាពស៊ីជម្រៅទាំងបីនោះ។

*Terjemahan ini hanya untuk tujuan informasi saja. Jika terdapat perbedaan, versi asli dalam bahasa Inggris yang akan berlaku.*